ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# ស្ត្រី និង បុរស នៅកម្ពុជា

ទិន្នន័យជាក់ស្តែងឆ្នាំ២០១៨

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

ភ្នំពេញ កម្ពុជា

**មាតិកា**

អារម្ភកថា..........
បុព្វកថា..........
សមភាពយេនឌ័រ..........
សេចក្តីផ្តើម..........
ប្រជាជន..........
សុខភាព..........
ការអប់រំ..........
កម្លាំងពលកម្ម..........
អំពើហិង្សា..........
ការធ្វើសេចក្តីសម្រេចចិត្ត..........
អក្សរកាត់..........

## អារម្ភកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង សូមបង្ហាញជូនកូនសៀវភៅអំពី "ស្ត្រី និងបុរសនៅកម្ពុជា" បោះពុម្ពផ្សាយលើកទីបួន ដែលបានផលិតឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ។ ស្ថិតិនេះបង្ហាញអំពីស្ថានភាពស្ត្រី និងបុរសលើផ្នែកផ្សេងៗជាច្រើនក្នុងជីវិតរស់នៅ។ តាមរយៈការបង្ហាញជូនពីស្ថានភាពសម្រាប់បុរសនិងស្ត្រីឲ្យមើលឃើញបានកាន់តែច្បាស់ ស្ថិតិនេះអាចនឹងរួមចំណែកទៅក្នុងការអភិវឌ្ឍជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា។ សមភាពយេនឌ័រគឺជាគោលដៅដ៏សំខាន់បំផុតមួយក្នុងបណ្តាគោលដៅទាំងឡាយនៃគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព (SDG) ឆ្នាំ 2015 ដល់ឆ្នាំ2030។

ខ្ញុំឆ្លៀតយកឱកាសនេះដើម្បីសម្តែងនូវអំណរគុណដល់ស្ថិតិស៊ុយអែត សម្រាប់ជំនួយបច្ចេកទេស អង្គការស៊ីដា (SIDA) និងអង្គការសហប្រជាជាតិដែលធ្វើការលើស្ត្រី (UN Woman) ដែលបានជួយឧបត្ថម្ភថវិការសម្រាប់ការផលិតកូនសៀវភៅនេះ។

លោកជំទាវ ហង់ លីណា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ ដែលបានជួយសម្របសម្រួលដល់កិច្ចដំណើរការផលិតសៀវភៅនេះ ដោយមានការជួយជ្រោមជ្រែងពីមន្ត្រីរបស់លោកជំទាវ និងក្រោមកិច្ចសហការជាមួយអ្នកដែលបានចូលរួមនៅក្នុងកម្មវិធីបណ្តុះ

បណ្ដាលអន្តរជាតិស្ដីពី "ស្ថិតិយេនឌ័រ" គឺលោកស្រី ឃិត រីវីយ៉ា លោកស្រី ជុំ ពុទ្ធីវណ្ណ មកពីវិទ្យាស្ថានជាតិស្ថិតិ, លោក សៅ វង្សវីរៈ មកពីក្រសួងកិច្ចការនារី, លោកស្រី កែវ ធីតា មកពី វិទ្យាស្ថានសភាកម្ពុជា, លោកស្រី ឌុន ថាវី មកពីអាជ្ញាធរ សវនកម្មជាតិកម្ពុជា និងលោកស្រី ថាក សុជាតិ មកពីអង្គការ កម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។ យើងខ្ញុំសូមថ្លែងអំណរគុណ ដល់អស់លោក-លោកស្រីទាំងអស់សម្រាប់ការចូលរួមយ៉ាង សកម្ម និងបានចូលរួមវិភាគទានក្នុងការចងក្រងផលិតកូន សៀវភៅនេះឡើង។

ឆាយ ថន

ទេសរដ្ឋមន្ត្រី

ក្រសួងផែនការ

ក្រសួងផែនការ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ខែមេសា ឆ្នាំ2018

## បុព្វកថា

នេះជាការបោះពុម្ពផ្សាយលើកទីបួននៃកូនសៀវភៅអំពី "ស្ត្រី និងបុរសនៅកម្ពុជា" ដែលបានផលិតឡើងដោយ ក្រុមការងារស្ថិតិយេនឌ័រ ដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ។ កូនសៀវភៅនេះផ្តល់ជូននូវទិដ្ឋភាពទូទៅរួមនៃស្ថានភាពស្ត្រី និងបុរសនៅកម្ពុជា ហើយនឹងត្រូវបានយកទៅប្រើប្រាស់ជាឯកសារដ៏មានសារៈប្រយោជន៍ស្តីពីស្ថិតិយេនឌ័រដែលអ្នកប្រើប្រាស់ដែលពាក់ព័ន្ធអាចយកទៅប្រើការបាន។

ការបោះពុម្ពផ្សាយនេះរួមមានតារាងតួលេខ និងក្រាហ្វិចដែលមានការវិភាគអធិប្បាយខ្លីៗ និងអាចប្រើប្រាស់ជាប្រភពព័ត៌មានសម្រាប់អ្នកប្រើប្រាស់គ្រប់រូបដែលមានចំណាប់អារម្មណ៍ទៅលើស្ថានភាពស្ត្រីនិងបុរស និងសមភាពយេនឌ័រនៅកម្ពុជា។ ព័ត៌មាននៅក្នុងកូនសៀវភៅនេះទទួលបានដំបូងបំផុតពីវិទ្យាស្ថានជាតិស្ថិតិ និងទីភ្នាក់ងារផលិតទិន្នន័យផ្សេងទៀតរបស់រដ្ឋាភិបាល។ ប្រភពព័ត៌មាននេះត្រូវបានផ្តល់ជូនស្របគ្នានឹងតារាងតួលេខ/ក្រាហ្វិចនីមួយៗ។ នៅក្នុងផ្នែកជាច្រើន តារាងនិងរូបភាពក្រាហ្វិចផ្តល់ជូននូវតួលេខ និង/ឬសមមាត្រ (%) សម្រាប់ជាការបង្ហាញជាក់លាក់អំពីស្ត្រីនិង/ឬបុរស។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារស្ថិតិយេនឌ័រនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងកិច្ចការនារី

វិទ្យាស្ថានសភាកម្ពុជា អាជ្ញាធរសវនកម្មកម្ពុជា និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការរៀបចំការបោះពុម្ពដ៏មានសារៈសំខាន់លើកទីបួននូវកូនសៀវភៅស្តីពីស្ត្រី និងបុរសនេះ។ សូមថ្លែងអំណរគុណជាពិសេសចំពោះស្ថិតិស៊ុយអែត សម្រាប់ការឧបត្ថម្ភគាំទ្រនិងជំនួយបច្ចេទេសរបស់ពួកគេ។

ហង់ លីណា
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក
វិទ្យាស្ថានជាតិស្ថិតិ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ខែមេសា ឆ្នាំ2018

## សមភាពយេនឌ័រ

សមភាពយេនឌ័រមានន័យថា ស្ត្រីនិងបុរសមានអំណាចស្មើគ្នាក្នុងការចូលរួមកសាងសង្គម និងកសាងជីវភាពផ្ទាល់ខ្លួនរបស់ពួកគេ។ នេះក៏មានន័យថា ស្ត្រី និងបុរសមានឱកាសមានសិទ្ធិ និងកាតព្វកិច្ចដូចៗគ្នា លើគ្រប់សកម្មភាពទាំងអស់ក្នុងការរស់នៅ។

សមភាពយេនឌ័រ គឺជាស្ថានភាពមួយដែលគ្មានការរើសអើងចំពោះភេទណាមួយនៅក្នុងការផ្តល់ធនធាន ឬប្រយោជន៍ ឬក្នុងការទទួលបានសេវាកម្មអ្វីមួយ។ សមភាពយេនឌ័រ អាចនឹងធ្វើការវាស់វែងលើការផ្តល់ឱកាសស្មើគ្នា ឬផលប្រយោជន៍ដែលទទួលបានស្មើគ្នា។ សន្និសីទអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ហៅកាត់ថា (CEDAW) អាចបញ្ជាក់អំពីឱកាសនៃសមភាពយេនឌ័រថា គួរតែមានការអនុវត្តជាក់ស្តែងលើគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាព និងគ្រប់វិស័យទាំងអស់នៃផ្នែកសេដ្ឋកិច្ច។

សមភាពយេនឌ័រមានន័យថាជាការប្រព្រឹត្តិដោយស្មើភាពគ្នារវាងស្ត្រី និងបុរស។ ដើម្បីធានាបាននូវភាពស្មើភាពគ្នា ការវាស់វែងត្រូវមានសម្រាប់ជាការតបស្នងចំពោះគុណវិបត្តផ្នែកសង្គមនឹងប្រវត្តិសាស្ត្រដែលបានរារាំងស្ត្រី និងបុរសមិនឲ្យមានឱកាសទទួលបានជោគជ័យស្មើភាពគ្នា។

សមធម៌មិនាំមកនូវសមភាព។ ការវាស់វែងជាច្រើនដែលដោះស្រាយបញ្ហាភាពខុសគ្នានានាដែលរាំងស្ត្រីមិនឲ្យមានឋានៈដូចគ្នាទៅនឹងបុរស នឹងធ្វើឲ្យស្ត្រីនិងបុរសអាចចែករំលែកលទ្ធផល និងអត្ថប្រយោជន៍នៃការអភិវឌ្ឍបានដោយស្មើភាពគ្នា។ ឧទាហរណ៍មួយនៃវង្វាស់សមធម៌នេះ គឺការផ្តល់ជូនការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី ដែលដោះស្រាយបញ្ហាវិសមភាពយេនឌ័រក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

## សេចក្តីផ្តើម

នៅក្នុងអាណត្តិទីប្រាំក្នុងឆ្នាំ2013 សមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីនៅតែជាបញ្ហាអាទិភាពសំខាន់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី III (2014-2018) បង្ហាញយ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ ដោយចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងសង្គម។

រដ្ឋាភិបាល តាមរយៈក្រសួងកិច្ចការនារី (MoWA) បានណែនាំឲ្យមានការលើកកម្ពស់ស្ថានភាពរបស់ស្ត្រី តាមរយៈការផ្តោតជាសំខាន់លើការវាស់វែងមួយចំនួនដូចជា ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការទទួលបានការអប់រំល្អសម្រាប់ស្ត្រីនិងក្មេងស្រី ការការពារផ្នែកផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ការលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី វត្តមានស្ត្រីក្នុងការសម្រេចចិត្ត និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយនិងកំណែទម្រង់កម្មវិធីរបស់រដ្ឋាភិបាល... ការពង្រឹងស្ថាប័ននិងការអភិវឌ្ឍសមត្ថភាពទៅរកសមភាពយេនឌ័រ ក៏ជាផ្នែកយកចិត្តចិត្តទុកដាក់ដ៏សំខាន់នៃផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី (2014-2018) ផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីនៅគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍ។ ដើម្បីសម្រេច

គោលបំណងនេះបាន ទាមទារឲ្យមាននូវចំណាត់ការជាក់ស្តែង និងកិច្ចសហការពីគ្រប់ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដែលពាក់ព័ន្ធ ដើម្បីធានាបាននូវបរិយាប័ន្នសម្រាប់មនុស្សគ្រប់គ្នា និងធានាថាគ្មាននរណាម្នាក់ត្រូវបានគេមើលរំលងឡើយ។

## ប្រជាជន

ជំពូកនេះ ពណ៌នាពីប្រជាជន ដោយរួមបញ្ចូលនូវផលធៀបបានមកពីការធ្វើជំរឿនឆ្នាំ1962 និងរចនាសម្ព័ន្ធអាយុ និងពីរ៉ាម៉ីតប្រជាជន និន្នាការព្យាករណ៍ចំនួនប្រជាជន ភាគរយនៃចរន្តបម្លាស់ទីលំនៅក្នុងស្រុកនិងក្រៅស្រុក ភាគរយនៃប្រជាជនមិនទាន់រៀបការតាមអាយុ និងអត្រាលទ្ធភាពបង្កើតកូនសរុប។ ផលធៀបភេទ ត្រូវបានកំណត់ថាជាចំនួនបុរសក្នុងចំណោមស្ត្រីចំនួន 100 នាក់ ក្នុងចំនួនប្រជាជនក្រុមណាមួយ។

ក្នុងជំរឿនលើកទីមួយឆ្នាំ1962 ផលធៀបភេទរបស់កម្ពុជា គឺមានចំនួនស្ទើរតែស្មើនឹង100។ តួលេខនេះបានធ្លាក់ចុះមកត្រឹម 86 នៅដើមទសវត្សរ៍ឆ្នាំ1980 ដោយសារតែអត្រាមរណភាពខ្ពស់របស់បុរសក្នុងអំឡុងរបបខ្មែរក្រហម។ តួលេខនេះបានកើនឡើងបន្តិចម្តងៗរហូតដល់ 93 នៅក្នុងជំរឿនឆ្នាំ 1998 និងមានចំនួន 95 នៅក្នុងជំរឿនឆ្នាំ2008 និង 94 នៅក្នុងកម្មវិធីអង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជា (CIPS) ឆ្នាំ2013 ដែលល្អៀងខុសគ្នាតិចតួចជាងតួលេខដែលមាននៅឆ្នាំ2008។

ជាមួយនឹងផលធៀបភេទប៉ាន់ប្រមាណចំនួន 96 ពីការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ2016 បង្ហាញថាប្រជាជនមានស្ត្រីចំនួន 7.9 លាននាក់ និងបុរសមានចំនួន 7.6 លាននាក់ ដោយស្ត្រីមានចំនួនច្រើនជាង 300 ពាន់នាក់។

ទោះបីជាតួលេខចាប់តាំងពីឆ្នាំ1998 ហាក់ដូចជាបង្ហាញពីការកើនឡើងក៏ដោយ តែស្ត្រីក៏នៅតែមានចំនួនច្រើនជាងបុរសដដែលនៅក្នុងចំនួនប្រជាជនកម្ពុជា។ ក្នុងបណ្ដាប្រទេសភាគច្រើននៅទូទាំងសាកលលោក ផលធៀបភេទអាចមានចំនួនពី 95 ដល់ 105។

## 1. ចំនួនប្រជាជនឆ្នាំ1962, 1980, 1994, 1996, 1998, 2008, 2013 និង2016

*ចំនួនគិតជាពាន់ និងផលធៀបភេទ*

| ឆ្នាំ | ប្រជាជន | | | ផលធៀបភេទ |
|---|---|---|---|---|
| | ស្រី | ប្រុស | សរុប | |
| 1962 | 2,866 | 2,863 | 5,729 | 99.9 |
| 1980 | * | * | * | 86.1 |
| 1994 | 5,156 | 4,714 | 9,870 | 91.4 |
| 1996 | 5,387 | 4,953 | 10,340 | 92.0 |
| 1998 | 5,926 | 5,511 | 11,438 | 93.0 |
| 2008 | 6,880 | 6,516 | 13,396 | 94.7 |
| 2013 | 7,555 | 7,122 | 14,677 | 94.3 |
| 2016 | 7,959 | 7,668 | 15,626 | 96.3 |

ប្រភព៖ ជំរឿនទូទៅនៃប្រជាជនរបស់ប្រទេសកម្ពុជា (GPCC) ឆ្នាំ1962, 1998, និង 2008, កម្មវិធីអង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជា (CIPS ) ឆ្នាំ2013, ការអង្កេតប្រជាសាស្ត្រទូទៅឆ្នាំ1980, ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ

1993-94, 1996, ការអង្កេតប្រជាសាស្ត្រឆ្នាំ1996, ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ2016 ដោយវិទ្យាស្ថានជាតិស្ថិតិ(NIS)។

"*"៖ ពុំអាចស្វែងរកបាន

តារាង 2 បង្ហាញពីព័ត៌មានស្តីពីភាគរយនៃប្រជាជនដែលរស់នៅតាមទីប្រជុំជន និងតាមទីជនបទក្នុងប្រទេសកម្ពុជា។ តាមការសង្កេតទៅលើលទ្ធផលនានា ភាគរយប្រជាជនបង្ហាញឲ្យឃើញថាមានប្រជាជនជាច្រើនដែលរស់នៅទីជនបទ (ប្រហែល 4 ដង) ច្រើនជាងអ្នកដែលរស់នៅទីប្រជុំជនសម្រាប់ចំនួនបុរសនិងស្ត្រីនៅប្រទេសកម្ពុជា ក្នុងជំរឿនឆ្នាំ 2008, កម្មវិធីសង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជា (CIPS) ឆ្នាំ2013 និងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ2016។

## 2. ចំនួនប្រជាជនតាមតំបន់ ឆ្នាំ2008, 2013 និង 2016

*គិតជាភាគរយ*

| | 2008 | | 2013 | | 2016 | |
|---|---|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស |
| ទីប្រជុំជន | 20 | 19 | 21 | 21 | 24 | 23 |
| ទីជនបទ | 80 | 81 | 79 | 79 | 76 | 77 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 |

ប្រភព៖ ជំរឿនទូទៅនៃប្រជាជនរបស់ប្រទេសកម្ពុជា (GPCC) ឆ្នាំ2008, កម្មវិធីសង្កេតចម្លោះជំរឿននៃប្រជាពលរដ្ឋ (CIPS) ឆ្នាំ2013 និងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ2016 ដោយវិទ្យាស្ថានជាតិស្ថិតិ។

រចនាសម្ព័ន្ធអាយុប្រជាជនត្រូវបានកំណត់ដោយកត្តាបីយ៉ាងដូចគ្នា ដែលមានឥទ្ធិពលលើអត្រាកំណើនប្រជាជន៖ លទ្ធភាពបង្កើតកូន មរណភាព និងចំណាកស្រុក។ ដើម្បីសិក្សាពីរចនាសម្ព័ន្ធអាយុប្រជាជន យើងសូមបង្ហាញពីការបែងចែកភាគរយនៃចំនួនប្រជាជនក្នុងក្រុមអាយុ និងភេទខុសៗគ្នាទៅតាមពីរ៉ាមីតប្រជាជន ដែលធ្វើការសង្ខេបត្រួសៗពីប្រវត្តិប្រជាសាស្ត្រនៃចំនួនប្រជាជន។ ភាគរយមនុស្សប្រុស និងស្រីតាមក្រុមអាយុប្រាំក្រុម គឺចាប់ផ្តើមឡើងដោយមានក្រុមអាយុក្មេងជាងគេនៅបាតក្រោមបំផុត និងកើនឡើងទៅតាមអាយុ មកផ្នែកកំពូលខាងលើបំផុតនៃពីរ៉ាមីត។ ភាគរយ

បុរសបង្ហាញនៅផ្នែកខាងស្តាំ ហើយភាគរយស្ត្រីនៅផ្នែកខាងឆ្វេងនៃចំណុចកណ្តាលរបស់ពីរ៉ាមីត។

ពីរ៉ាមីតប្រជាជនបង្ហាញថា ចំណែកនៃប្រជាជនកុមារអាយុ (0-14ឆ្នាំ) បានថយចុះពី 18 ភាគរយនៅឆ្នាំ2008 ទៅ 16 ភាគរយនៅឆ្នាំ2013 សម្រាប់បុរស និងបានកើនឡើងពី 13 ភាគរយក្នុងឆ្នាំ2008 ទៅដល់ 14 ភាគរយនៅក្នុងឆ្នាំ2013 សម្រាប់ស្ត្រី។

ភាគរយនៃក្រុមប្រជាជនដល់អាយុធ្វើការ (អាយុ 15-64 ឆ្នាំ) នៅប្រទេសកម្ពុជា បានកើតឡើងពី 30 ភាគរយ ទៅ 31 ភាគរយសម្រាប់បុរស និងបានកើតឡើងពី 32 ភាគរយ ទៅ 34 ភាគរយសម្រាប់ស្ត្រី ដែលមានកំណើនជិតភាគរយ។ ចំនួនប្រជាជនវ័យចំណាស់ (អាយុ 65 ឆ្នាំឡើងទៅ) នៅក្នុងប្រទេសទាំងមូលបានកើនឡើងពី 1.7 ភាគរយទៅ 2.0 ភាគរយសម្រាប់បុរស និងបានកើនឡើងពី 2.5 ភាគរយទៅ 3.0 ភាគរយសម្រាប់ស្ត្រី។

## 3. ចំនួនប្រជាជនតាមអាយុ ឆ្នាំ2008 និង ឆ្នាំ2013

*ការបែងចែកភាគរយ*

2008


ស្រី
ប្រុស
75+
70-74
65-69
60-64
55-59
50-54
45-49
40-44
35-39
30-34
25-29
20-24
15-19
10-14
5-9
0-4
8 6 4 2 0 2 4 6 8
ភាគរយ

2013




ប្រភព៖ ជំរឿនទូទៅនៃប្រជាជនរបស់ប្រទេសកម្ពុជា (GPCC) ឆ្នាំ2008, កម្មវិធីសង្កេតចម្លោះជំរឿននៃប្រជាពលរដ្ឋ (CIPS) ឆ្នាំ2013 ដោយវិទ្យាស្ថានជាតិស្ថិតិ។

ប្រជាជនកម្ពុជានឹងមានចំនួនកើនឡើងប្រហែល 2.6 លាននាក់អំឡុងឆ្នាំ2013-2023 នេះបើយោងតាមការព្យាករណ៍ចំនួនប្រជាជនប្រទេសកម្ពុជា។ ក្នុងឆ្នាំ2023 ចំនួនមនុស្សប្រុសនឹងមានចំនួន 8.8 លាននាក់ ហើយចំនួនមនុស្សស្រីនឹងមានចំនួន 8.5 លាននាក់។

## 4. ការព្យាករណ៍ចំនួនប្រជាជនប្រទេសកម្ពុជា

*គិតជាលាននាក់*




ប្រភព៖ ការព្យាករណ៍ចំនួនប្រជាជនប្រទេសកម្ពុជាឆ្នាំ 2008-2050 ដោយវិទ្យាស្ថានជាតិស្ថិតិ។

ក្នុងចំណោមប្រជាជនផ្លាស់ទីលំនៅក្នុងស្រុក អ្នកដែលផ្លាស់ទីលំនៅពីជនបទទៅជនបទមានចំនួនច្រើននៅក្នុងឆ្នាំ2008 និងឆ្នាំ2013 ដែលមានសមមាត្រកើនឡើងនៅក្នុងឆ្នាំ2013។ សមមាត្រនៃប្រជាជនផ្លាស់ទីលំនៅពីជនបទទៅទីប្រជុំជន ក៏ដូចជាប្រជាជនផ្លាស់ទីលំនៅពីទីប្រជុំជនទៅទីប្រជុំជនដែរ គឺបានថយចុះ 4 ភាគរយសម្រាប់ស្ត្រី និងត្រឹម 2 ភាគរយសម្រាប់បុរសក្នុងអំឡុងពេលប្រាំឆ្នាំ ដែលភាគរយស្ត្រីមានចំនួនមួយភាគបួននៃប្រជាជនផ្លាស់ទីលំនៅក្នុងស្រុក ហើយ

ភាគរយបុរសមានចំនួនស្មើតែស្មើនឹងពាក់កណ្ដាលនៃភាគរយស្រ្តីនៅក្នុងឆ្នាំ2013។

## 5. ការផ្លាស់ទីលំនៅពីទីប្រជុំជនទៅជនបទ ឆ្នាំ2008 និងឆ្នាំ 2013

*តួលេខជាភាគរយ និងតួលេខសរុប*

| ចរន្តនៃការផ្លាស់ទីលំនៅ | 2008 | | 2013 | |
|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស |
| ពីជនបទទៅជនបទ | 49 | 53 | 57 | 60 |
| ពីជនបទទៅទីប្រជុំជន | 30 | 26 | 26 | 24 |
| ពីទីប្រជុំជនទៅជនបទ | 6 | 7 | 5 | 5 |
| ពីទីប្រជុំជនទៅទីប្រជុំជន | 16 | 14 | 13 | 11 |
| សរុប | 100 | 100 | 100 | 100 |
| ចំនួនសរុប | 1,710,000 | 1,742,000 | 2,049,000 | 2,085,000 |

ប្រភព៖ ជំរឿនទូទៅនៃប្រជាជនរបស់ប្រទេសកម្ពុជា (GPCC) ឆ្នាំ2008, កម្មវិធីសង្កេតចម្លោះជំរឿននៃប្រជាពលរដ្ឋ (CIPS) ឆ្នាំ2013 ដោយវិទ្យាស្ថានជាតិស្ថិតិ។

ក្នុងឆ្នាំ2015 និងឆ្នាំ2016 ចំនួនជនចំណាកស្រុកទៅក្រៅប្រទេសទៅកាន់ប្រទេសថៃមានចំនួនខ្ពស់បំផុត ហើយបានកើនឡើងពី 79 ភាគរយដល់ 92 ភាគរយសម្រាប់ស្ត្រី និងពី 73 ភាគរយដល់ 88 ភាគរយសម្រាប់បុរស។ តួលេខបន្ទាប់នៃជនចំណាកស្រុកទៅក្រៅប្រទេសបានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងប្រទេសកូរ៉េ និងប្រទេសជប៉ុន ហើយបន្ទាប់មកគឺនៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបូរីដែលមានចំនួនខុសគ្នាបន្តិចបន្តួចស្ថិតនៅលំដាប់បន្ទាប់។ មានតែការធ្វើចំណាកស្រុកទៅក្រៅប្រទេសដែលបានចុះបញ្ជីដោយក្រុមហ៊ុន ឯកជនតែប៉ុណ្ណោះ ដែលត្រូវបានរាប់បញ្ចូលក្នុងតារាងនេះ។

## 6. ការធ្វើចំណាកស្រុកទៅក្រៅប្រទេសដែលបានចុះបញ្ជីដោយក្រុមហ៊ុនឯកជន

*គិតជាភាគរយ*

| ចរន្តនៃការផ្លាស់ទី | 2015 | | 2016 | |
|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស |
| ម៉ាឡេស៊ី | 4 | 1 | 0 | 0 |
| ថៃ | 79 | 73 | 92 | 88 |
| ជប៉ុន | 6 | 2 | 3 | 1 |
| សិង្ហបុរី | 1 | - | 0 | - |
| កូរ៉េ | 11 | 24 | 5 | 11 |
| សរុប | 100 | 100 | 100 | 100 |

ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ2016, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ការធ្វើចំណាកស្រុកដែលបានចុះបញ្ជីដោយ ក្រុមហ៊ុនឯកជន)

ព័ត៌មានគ្រួសារ

ស្ថានភាពអាពាហ៍ពិពាហ៍ គឺជាកត្តាដ៏សំខាន់នៅក្នុងឌីណាមិចប្រជាជន ដោយសារតែវាជះឥទ្ធិពលលើលទ្ធភាពបង្កើតកូន និងមរណភាព ក៏ដូចជាធ្វើចំណាកស្រុកក្នុងកម្រិតតិចតួចណាមួយដែរ។ តារាងនេះបង្ហាញពីការបែងចែកភាគរយនៃមនុស្សប្រុសនិងមនុស្សស្រីដែលមានអាយុ 15 ឆ្នាំនិងលើសពីនេះ ទៅតាមក្រុមអាយុចំនួនប្រាំក្រុមដែលមិនទាន់រៀបការ។ ចម្លើយចំពោះសំណួរទាក់ទងនឹងស្ថានភាពអាពាហ៍ពិពាហ៍ នៅក្នុងការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ត្រូវបានបែងចែកជាក្រុមតាមប្រភេទដូចជា៖ មិនធ្លាប់រៀបការ និងធ្លាប់រៀបការ (បច្ចុប្បន្ន មានគ្រួសារ មេម៉ាយ/ពោះម៉ាយ លែងលះ និងរស់នៅបែកគ្នា)។ បុគ្គលម្នាក់ត្រូវបានចាត់ទុកថាបានរៀបការរួច បើតាមច្បាប់ ឬទំនៀមទម្លាប់ប្រពៃណីក្នុងស្រុក បុគ្គលនោះត្រូវបានគេដឹងឮនិងទទួលស្គាល់ថាបានរៀបការរួច ឬរស់នៅជាមួយបុគ្គលម្នាក់ផ្សេងទៀតដែលមានភេទផ្ទុយគ្នាក្នុងនាមជាស្វាមីភរិយា។

គេបានអង្កេតឃើញថា សមមាត្រខ្ពស់បំផុតនៅក្នុងក្រុមអាយុពី 15-19 ឆ្នាំ ជាអ្នកនៅលីវ ដែលក្នុងនោះ 92 ភាគរយជាមនុស្សស្រី និង 98 ភាគរយចាមនុស្សប្រុស។ ក្នុងក្រុមអាយុ 30-34 ឆ្នាំ សមមាត្រនៃអ្នកដែលមិនធ្លាប់រៀបការ គឺមានចំនួនថយចុះ 1 ភាគរយសម្រាប់ភេទប្រុសនិងភេទស្រីនៅចន្លោះឆ្នាំ2014 និងឆ្នាំ2016។ ប្រជាជនភាគច្រើនដែលមានអាយុលើសពី 50 ឆ្នាំដែល "ពុំធ្លាប់រៀបការ" គឺបន្តរស់នៅដោយមិនយកប្ដីប្រពន្ធអស់មួយជីវិត។

## 7. ចំនួនប្រជាជនដែលមិនធ្លាប់រៀបការតាមក្រុមអាយុ ឆ្នាំ 2014 និង 2016

*ជាភាគរយ*




ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ2014 និងឆ្នាំ2016 ដោយវិទ្យាស្ថានជាតិស្ថិតិ។

នៅឆ្នាំ2014 អត្រាលទ្ធភាពបង្កើតកូនសរុប (TFR) នៅក្នុងប្រទេកម្ពុជាគឺមាន 2.7 នាក់សម្រាប់ស្ត្រីម្នាក់។ ជាមធ្យម ស្ត្រីនៅជនបទនឹងផ្តល់កំណើតដល់ទារកប្រហែល 2.9 នាក់អំឡុងពេលលទ្ធភាពបន្តពូជរបស់ពួកគេ ចំណែកស្ត្រីនៅទីប្រជុំជនអាចផ្តល់កំណើតដល់ទារកតែត្រឹម 2.1 នាក់ប៉ុណ្ណោះក្នុងអំឡុងពេលនៃលទ្ធភាពបន្តជូជរបស់ពួកគេ ប្រសិនបើពួកគេអនុវត្តតាមកម្រិតលទ្ធភាពបង្កើតកូនបច្ចុប្បន្នពេញមួយជីវិតរបស់ពួកគេ។ អត្រាលទ្ធភាពបង្កើតកូនសរុបបានថយចុះក្នុងរយៈពេល 15 ឆ្នាំកន្លងមកនេះ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ2000 និងឆ្នាំ2005 បានប៉ាន់ប្រមាណថា ចំនួនកូនដែលស្ត្រីជាមធ្យមអាចមាននៅក្នុងជីវិតរស់នៅរបស់គេ គឺមានចំនួន 4.0 និង 3.4 នាក់សម្រាប់ស្ត្រីម្នាក់តាមលំដាប់ឆ្នាំនៃការអង្កេតទាំងពីរខាងលើ។ មកត្រឹមឆ្នាំ2010 អាត្រាលទ្ធភាពបង្កើតកូនសរុបបានបន្តធ្លាក់ចុះត្រឹម 3.0 នាក់សម្រាប់ស្ត្រីម្នាក់។

## 8. អត្រាលទ្ធភាពបង្កើតកូនសរុប (15-49), ឆ្នាំ 2000, 2005, 2010 និង 2014

*ចំនួនកូនក្នុងស្ត្រីម្នាក់*




ប្រភព៖ ការអង្កេតប្រជាសាស្រ្ត និងសុខភាពឆ្នាំ2000, 2005, 2010 និង 2014 ដោយវិទ្យាស្ថានជាតិស្ថិតិ។

# សុខភាព

ជំពូកនេះ បង្ហាញពីព័ត៌មានសំខាន់ៗស្តីពីអាយុកាលសង្ឃឹមរស់ជាមធ្យម ចំណេះដឹងអំពីការពន្យារកំណើត និងការថែទាំមុនពេលសម្រាលកូនដោយផ្តោតជាសំខាន់លើការផ្តល់ជំនួយក្នុងអំឡុងពេលឆ្លងទន្លេ អត្រាមរណភាពមាតា និងទំនោរនៃអត្រាមរណភាពទារក។ ទិន្នន័យនេះ ពាក់ព័ន្ធនឹងគោលនយោបាយអាទិភាពទិសដៅសំខាន់ៗចំនួនបួននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ2014 ដល់ឆ្នាំ2018 ដែលបានអនុវត្តដោយក្រសួងសុខាភិបាលដើម្បីសម្រេចបាននូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទីប្រាំនៃរដ្ឋសភា ហើយទិន្នន័យទាំងនេះគឺជាក្របខណ្ឌសូចនាករដ៏សំខាន់សម្រាប់ការគ្រប់គ្រងតាមដាននិងវាយតម្លៃ។

អាយុកាលសង្ឃឹមរស់ជាមធ្យមនៅពេលកើតបានកើនឡើងជាពិសេសសម្រាប់ស្ត្រីដែលមានអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ខ្លួនបានកើនឡើងលើសពីដប់ឆ្នាំ ចាប់ពីឆ្នាំ1998 ដល់ឆ្នាំ2013។ ទំនោរនៃការព្យាករណ៍អាយុរបស់ស្ត្រី អាចនឹងកើនឡើងដល់ជាង 76 ឆ្នាំ ក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ផងដែរ។ ស្ត្រីត្រូវបានគេព្យាករណ៍ថានឹងមានអាយុវែងជាងបុរស។

1. អាយុកាលសង្ឃឹមរស់ជាមធ្យមនៅពេលកើត។ បានអង្កេតនៅឆ្នាំ1995, 2000, 2005, 2010 និង 2015 និងការព្យាករណ៍ឆ្នាំ2020 ដល់ឆ្នាំ2023




ប្រភព៖ ការព្យាករណ៍ចំនួនប្រជាជនកម្ពុជា ឆ្នាំ2013-2023, វិទ្យាស្ថានជាតិស្ថិតិ។

ការប្រើប្រាស់វិធីពន្យារកំណើតក្នុងពេលបច្ចុប្បន្នក្នុងចំណោមស្ត្រីនៅប្រទេសកម្ពុជា គឺបន្តកើនឡើងពីកម្រិតដែលបាន

រាយការណ៍ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ2000 ដល់ឆ្នាំ2014។ ក្នុងរយៈពេល 14 ឆ្នាំចុងក្រោយនេះ ស្ត្រីទំនងជានឹងប្រើប្រាស់វិធីសាស្ត្រទំនើបៗកាន់តែច្រើនឡើង។ តួលេខបានកើនឡើងពី 19 ភាគរយទៅ 39 ភាគរយ។ ទន្ទឹមគ្នានេះ ក៏មានការប្រើប្រាស់វិធីសាស្ត្របូរាណផងដែរ ក្នុងបណ្តាវិធីសាស្ត្រសំខាន់ៗទាំងនោះ វិធីសាស្ត្រចាក់ទឹកក្រៅពាងត្រូវបានគេអនុវត្ត។ វិធីតមមិនរួមភេទក៏ត្រូវបានគេប្រើប្រាស់ក្នុងបរិមាណប្រហាក់ប្រហែលគ្នានេះដែរ នៅចន្លោះឆ្នាំនោះ។

**2. ការបែងចែកស្ត្រីរៀបការរួចក្នុងក្រុមអាយុ 15-49 ឆ្នាំ ដែលប្រើប្រាស់វិធីពន្យារកំណើតក្នុងពេលបច្ចុប្បន្ន។ ឆ្នាំ2000, 2005, 2010 និង 2014**

*គិតជាភាគរយ*

| វិធីសាស្ត្រ | 2000 | 2005 | 2010 | 2014 |
|---|---|---|---|---|
| វិធីសាស្ត្រណាមួយ | 24 | 40 | 51 | 56 |
| វិធីសាស្ត្រទំនើបណាមួយ | 19 | 27 | 35 | 39 |
| វះចងដៃស្បូន | 2 | 2 | 2 | 3 |
| ថ្នាំគ្រាប់ប្រចាំថ្ងៃ/ | 7 | 13 | 16 | 18 |

| | | | | |
|---|---|---|---|---|
| ប្រចាំខែ | | | | |
| កងដាក់ក្នុងស្បូន | 1 | 2 | 3 | 4 |
| ថ្នាំចាក់ | 7 | 8 | 10 | 9 |
| ស្រោមអនាម័យបុរស | 1 | 3 | 3 | 2 |
| កងដាក់ដៃ | 0 | 0 | 0 | 2 |
| វិធីសាស្ត្របែបបុរាណណាមួយ | 5 | 13 | 16 | 18 |
| តមមិនរួមភេទ | 3 | 5 | 4 | 3 |
| វិធីសាស្ត្រចាក់ទឹកក្រៅពោង | 2 | 8 | 12 | 15 |
| មិនទាន់ប្រើប្រាស់នាពេលបច្ចុប្បន្ន | 76 | 60 | 50 | 44 |
| សរុប | 100 | 100 | 100 | 100 |
| ចំនួនស្ត្រីក្នុងការអង្កេត | 9,100 | 10,100 | 11,600 | 11,900 |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014

ការថែទាំពេលសម្រាលដោយអ្នកផ្តល់សេវាដែលទទួលបានការបណ្តុះបណ្តាលនៅក្នុងអំឡុងពេលឆ្លងទន្លេ គឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយមរណភាពមាតានិង

ទារក។ ម្ដាយដែលមានអាយុក្រោម 20 ឆ្នាំ មានភាគរយនៃការសម្រាលកូនជាមួយគ្រូពេទ្យឆ្មបក្នុងអំឡុងពេលសម្រាលច្រើនជាង (74%) ម្ដាយដែលមានអាយុចន្លោះពី 35 ទៅ 49 ឆ្នាំ (66%)។ ចំពោះម្ដាយដែលមានអាយុច្រើនជាងនេះ តែងសម្រាលកូនជាមួយឆ្មបបុរាណក្នុងចំនួនច្រើនជាងម្ដាយដែលមានវ័យក្មេង។

### 3. កំណើតទទួលបានជំនួយពីអ្នកផ្ដល់សេវាជំនាញ ឆ្នាំ2014

*ការបែងចែកភាគរយ*

| អ្នកផ្ដល់ជំនួយអំឡុងពេលសម្រាលកូន | | | | | |
|---|---|---|---|---|---|
| | វេជ្ជបណ្ឌិត | គិលានុបដ្ឋាក | ពេទ្យឆ្មប | ឆ្មបបូរាណ | ផ្សេងៗ |
| អាយុម្ដាយនៅពេលផ្ដល់កំណើតកូន | | | | | |
| <20 | 11 | 4 | 74 | 11 | 0 |
| 20-34 | 16 | 3 | 70 | 10 | 0 |
| 35-49 | 13 | 3 | 66 | 18 | 1 |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014

## មរណភាពមាតា

មានករណីមរណភាពមាតាចំនួន 32 ករណីក្នុងរយៈពេលប្រាំមួយឆ្នាំនេះ ចន្លោះឆ្នាំ2008 និងឆ្នាំ2014។ ការស្លាប់របស់ម្តាយមានចំនួនប្រាំបូនភាគរយក្នុងបណ្តាស្ត្រីដែលបានទទួលមរណភាពទាំងអស់។ នេះមានន័យថា ស្ត្រី 1 នាក់ក្នុងចំណោមស្ត្រីកម្ពុជា 11 នាក់បានស្លាប់ក្នុងរយៈពេលនេះ ដែលនេះគឺជាតួលេខប្រចាំឆ្នាំនៃមរណភាពមាតាក្នុងស្ត្រី 1000 នាក់ អាយុពី 15-49 ឆ្នាំ។

### 4. មរណភាពមាតា ឆ្នាំ 2008-2014 តាមក្រុមអាយុប្រាំឆ្នាំ។

*តួលេខ និងភាគរយនៃមរណភាពស្ត្រីទាំងអស់*

| អាយុ | ភាគរយនៃការស្លាប់របស់ស្ត្រីដែលជាមាតា | ការស្លាប់របស់ម្តាយ |
|---|---|---|
| 15-19 | 0 | 0 |
| 20-24 | 13 | 4 |
| 25-29 | 27 | 11 |
| 30-34 | 11 | 5 |
| 35-39 | 16 | 8 |
| 40-44 | 3 | 2 |
| 45-49 | 3 | 2 |
| 15-49 | 9 | 32 |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014

មរណភាពទារក

លទ្ធផលនៃការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាឆ្នាំ 2014 ធៀបជាមួយនឹងលទ្ធផលស្រាវជ្រាវពីឆ្នាំ2000, 2005, និង 2010 បានបង្ហាញថា អត្រាមរណភាពទារកបានថយចុះបន្តិចម្តងៗជាលំដាប់ក្នុងរយៈពេល 14 ឆ្នាំចុងក្រោយ ដោយថយចុះពីការស្លាប់ចំនួន 95 នាក់ក្នុង 1000 កំណើតរស់នៅឆ្នាំ2000 មកត្រឹមការស្លាប់ចំនួន 28 នាក់ក្នុង 1000 កំណើតរស់នៅឆ្នាំ2014។ ម្យ៉ាងទៀត ការអង្កេតនេះបានបង្ហាញថា អត្រាមរណភាពរបស់ក្មេងស្រីគឺមានចំនួនតិចជាងអត្រាមរណភាពរបស់ក្មេងប្រុសនៅក្នុងជីវិតរស់នៅមុនអាយុ 5 ឆ្នាំ។

**5. មរណភាពទារក ឆ្នាំ2000, 2005, 2010 និង 2014**

*មរណភាពក្នុង រស់កំណើត 1000*



ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014

លើសពីនេះទៅទៀត អត្រាមរណភាពទារក តាមលក្ខណៈសេដ្ឋកិច្ចសង្គមនៅតាមទីប្រជុំជន មានចំនួនទាបជាងទីជនបទ។ម្យ៉ាងទៀត មរណភាពបានថយចុះគួរឲ្យកត់សម្គាល់ដោយសារតែការកើនឡើងនូវកម្រិតការអប់រំរបស់ម្តាយ។ ម្តាយដែលមានការអប់រំកម្រិតទាប ឬមិនបានចូលរៀនបានប្រឈមមុខទៅនឹងអត្រាមរណភាពខ្ពស់ ដែលមានចំនួន 63 ករណី បើធៀបទៅនឹងការស្លាប់ 26 ករណីក្នុងចំណោម 1000 កំណើតរស់ សម្រាប់អ្នកដែលទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សា។

### 6. អត្រាមរណភាពទារក តាមលក្ខណៈសេដ្ឋកិច្ចសង្គម ឆ្នាំ 2014

*មរណភាពក្នុង 1000កំណើតរស់*




ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014

## សុខភាព

ស្ត្រីមានទំនោរទៅរកភាពមានសុខភាពមិនល្អច្រើនជាងបុរសគ្រប់ផ្នែកទាំងអស់ ទាំងនៅភ្នំពេញ ទីប្រជុំជន និងទីជនបទ។ ភាគរយរបស់ស្ត្រីខ្ពស់ជាងបុរសនៅក្នុងផ្នែកនានា បានធ្លាក់ខ្លួនឈឺ រងរបួស ឬមានបញ្ហាសុខភាព ជាពិសេសស្ត្រីដែលរស់នៅទីជនបទ។

### 7. ជំងឺ/ការរងរបួសក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ នៅឆ្នាំ 2015។

*គិតជាភាគរយ*




ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ2015

ក្នុងប្រទេសកម្ពុជា ស្ទើរតែ 100 ភាគរយនៃស្ត្រីនិងបុរស អាយុពី 15 ឆ្នាំដល់ 49 ឆ្នាំ ទាំងនៅទីប្រជុំជន និងទីជនបទ បានដឹងអំពីវីរុសហ៊ីវ/ជំងឺអេដស៍។

## 8. ស្ត្រី និងបុរសអាយុពី 15-49 ឆ្នាំដែលធ្លាប់បានឮអំពីជំងឺអេដស៍គិតតាមតំបន់ ឆ្នាំ2014

*ភាគរយ និងតួលេខក្នុងការអង្កេត*

| តំបន់ | ស្រី | | ប្រុស | |
|---|---|---|---|---|
| | ធ្លាប់បានឮអំពីជំងឺអេដស៍ | ចំនួនអ្នកឆ្លើយសំណួរ | ធ្លាប់បានឮអំពីជំងឺអេដស៍ | ចំនួនអ្នកឆ្លើយសំណួរ |
| ទីប្រជុំជន | 100 | 3,251 | 99 | 869 |
| ទីជនបទ | 98 | 14,327 | 98 | 4,321 |

ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ2014។

# ការអប់រំ

ជំពូកនេះ ផ្តល់ព័ត៌មានអំពីអក្ខរកម្មតាមក្រុមអាយុ អត្រាចុះឈ្មោះចូលរៀន (អាត្រាចូលរៀនពិត និងអត្រារួម) តាមកម្រិតភូមិសិក្សា អាត្រាបោះបង់ការសិក្សា និងមូលហេតុនៃការបោះបង់សាលា ការចំណាយលើការអប់រំ និងភាគរយសិស្សនៅថ្នាក់ក្រោមបរិញ្ញាបត្រ/បញ្ចប់បរិញ្ញាបត្រ។

អក្ខរកម្ម

អត្រាអក្ខរកម្មមនុស្សពេញវ័យ គឺជាចំណែកនៃប្រជាជនអាយុពី 15 ឆ្នាំឡើងទៅ ដែលចេះអាននិងសរសេរសារធម្មតាក្នុងភាសាណាមួយបាន។ អត្រាអក្ខរកម្មនៅប្រទេសកម្ពុជាមានចំនួនច្រើនជាងគេបំផុតក្នុងចំណោមមនុស្សស្រីនិងមនុស្សប្រុសនៅក្នុងក្រុមអាយុ 15-24 ឆ្នាំ ទាំងនៅឆ្នាំ2014 និងឆ្នាំ2016 ហើយបន្ទាប់មកគឺនៅក្នុងបណ្តាលក្រុមអាយុ 25-34 ឆ្នាំ។ ជាទូទៅ អត្រាអក្ខរកម្មក្នុងចំណោមបុរស គឺខ្ពស់ជាងស្ត្រីនៅគ្រប់ក្រុមអាយុទាំងអស់ លើកលែងតែក្រុមអាយុ 6-14 ឆ្នាំ និង 15-24 ឆ្នាំ ដែលអត្រាអក្ខរកម្មក្នុងចំណោមស្ត្រីមានចំនួនខ្ពស់ជាងនៅក្នុងបណ្តាឆ្នាំទាំងពីរក្រុមខាងលើនេះ។ អត្រាអក្ខរកម្មពីអាយុ 6 ឆ្នាំឡើងទៅ ក្នុងចំណោមស្ត្រីនិងបុរសនៅក្នុងឆ្នាំ2016 គឺខ្ពស់ជាងឆ្នាំ2014។

**1. អក្ខរកម្មតាមក្រុមអាយុ ឆ្នាំ2014 និង 2016**

*គិតជាភាគរយ*




ប្រភព៖ ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ 2014 និងឆ្នាំ2016 ដោយវិទ្យាស្ថានជាតិស្ថិតិ។

ក្រាហ្វិចនេះ បង្ហាញថា អត្រាអក្ខរកម្មក្នុងបណ្ដាបុរសនិងស្ត្រីនៅតាមទីប្រជុំជន គឺមានចំនួនខ្ពស់ជាងបុរសនិងស្ត្រីនៅតាមទីជនបទនៅគ្រប់ក្រុមឆ្នាំទាំងអស់។ អត្រាអក្ខរកម្មមនុស្សពេញវ័យនៃប្រជាជនអាយុ 15 ឆ្នាំឡើងទៅ គឺស្ត្រីមានកម្រិតទាបជាងបុរសនៅគ្រប់តំបន់ទាំងអស់។

**2. អក្ខរកម្ម (អាយុ 15 ឆ្នាំឡើងទៅ) តាមតំបន់ភូមិសាស្ត្រ ឆ្នាំ 2014, 2015 និង 2016។**

*គិតជាភាគរយ*




ប្រភព៖ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ2014, 2015 និង 2016 ដោយវិទ្យាស្ថានជាតិស្ថិតិ។

## អត្រាចុះឈ្មោះចូលរៀន

អត្រាចុះឈ្មោះចូលរៀន ឬអត្រាចូលរៀនពិត (NER) គឺបានកំណត់ជាភាគរយនៃតួលេខកុមារ ឬសិស្សនៅក្នុងក្រុមអាយុដែលបានសន្មតសម្រាប់ភូមិសិក្សាណាមួយដែលបានចូលរៀននៅក្នុងកម្រិតសិក្សានោះ និងបានបង្ហាញជាភាគរយចំពោះចំនួនប្រជាជនសរុបនៅក្នុងក្រុមអាយុនោះ។ ទិន្នន័យស្ថិតិមូលដ្ឋានក្រសួងអប់រំ (EMIS) បង្ហាញថា ភាគរយ គឺគិតចាប់ពីចំនួន 84 ភាគរយក្នុងចំណោមក្មេងស្រី និង 90 ភាគរយសម្រាប់ក្មេងប្រុស និងបានកើនឡើងបន្តិចពីឆ្នាំសិក្សា 2001-2002 ទៅជា 97 ភាគរយក្នុងឆ្នាំសិក្សា2012-2013 ប៉ុន្តែភាគរយនេះបានថយចុះបន្តិចទាំងសិស្សប្រុសនិងសិស្ស

ស្រីក្នុងឆ្នាំសិក្សា2013-2014 និងបានថយចុះបន្តិចទៀតក្នុងឆ្នាំសិក្សា2015-2016។ អត្រាចុះឈ្មោះចូលរៀន គឺមានចំនួន 95 ភាគរយសម្រាប់ក្មេងប្រុស និង 93 ភាគរយសម្រាប់ក្មេងស្រីដែលបានចូលរៀននៅកម្រិតបឋមសិក្សាក្នុងឆ្នាំសិក្សា 2015-2016។ ជាទូទៅ អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស មានកម្រិតខ្ពស់ជាងក្មេងស្រីនៅគ្រប់ឆ្នាំទាំងអស់ លើកលែងតែឆ្នាំ2012 ដល់ 2016 ដែលអត្រាចុះឈ្មោះចូលរៀនមានភាពខុសគ្នាតែបន្តិចបន្តួចបណ្ដោះ។

## 3. អត្រាចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា

*គិតជាភាគរយ*




ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំ យុវជន និងកីឡា

អត្រាចូលរៀនរួម (GER) ត្រូវបានកំណត់ជាភាគរយសម្រាប់កុមារ ឬសិស្សដែលបានចុះឈ្មោះចូលរៀននៅភូមិសិក្សាណាមួយ ដោយពុំគិតពីអាយុឡើយ និងមានទំនាក់ទំនងជាមួយចំនួនប្រជាជននៅក្នុងក្រុមអាយុដែលបានសន្មតសម្រាប់ភូមិសិក្សាដូចគ្នា។ តារាងនេះ បង្ហាញពីអត្រាចូលរៀនរួមនៅថ្នាក់មធ្យមសិក្សាបឋមភូមិ គឺមាន 55 ភាគរយកើនឡើង 2 ភាគរយ និង 3 ភាគរយសម្រាប់ក្មេងស្រី ពីឆ្នាំ 2014 ដល់ឆ្នាំ2017 នៅក្នុងប្រទេសកម្ពុជា និងនៅតំបន់ជនបទ ប៉ុន្តែបានថយចុះ 3 ភាគរយ និង 2 ភាគរយនៅតំបន់ទីប្រជុំជន។ អត្រាចូលរៀនពិតដែលមានភាពស៊ីចង្វាក់គ្នានេះបានប្រែប្រួលតិចតួចប៉ុណ្ណោះក្នុងរយៈពេល 3 ឆ្នាំចុងក្រោយ (2014-2017) សម្រាប់ក្មេងប្រុស។

*.4អត្រាចូលរៀនពិតនៅមធ្យមសិក្សាបឋមភូមិ ឆ្នាំ 2014 ជាភាគរយ 2017ដល់ឆ្នាំ*

| | 2014-2015 | | 2015-2016 | | 2016-2017 | |
|---|---|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | 55 | 52 | 57 | 51 | 60 | 52 |
| ទីប្រជុំជន | 59 | 58 | 56 | 55 | 57 | 54 |
| ទីជនបទ | 55 | 50 | 57 | 50 | 60 | 52 |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំ យុវជន និងកីឡា

ក្នុងតារាង 2.2 យើងឃើញថា ប្រជាជននៅទីប្រជុំជនមានអត្រាចូលរៀនរួមខ្ពស់នៅកម្រិតមធ្យមសក្សាទុតិយភូមិក្នុងឆ្នាំសិក្សា 2016-2017 សម្រាប់មនុស្សពេញវ័យអាយុ 15-17 ឆ្នាំ ដែលត្រូវជា 39 ភាគរយសម្រាប់ស្ត្រី និង 38 ភាគរយសម្រាប់បុរស។ អត្រាទាបជាងនេះ គឺឃើញមាននៅតាមតំបន់ជនបទ ដែលការចូលរៀនរួមក្នុងចំណោមស្ត្រី គឺមានប្រហែល 23 ភាគរយ និងប្រហែល 20 ភាគរយសម្រាប់បុរស។ នៅចន្លោះឆ្នាំ2014-2015 និងឆ្នាំ2016-2017 អត្រាចូលរៀនរួមនៅកម្រិតមធ្យសិក្សាទុតិយភូមិ គឺទាបជាងតិចតួចសម្រាប់ស្ត្រី និងគ្មានការប្រែប្រួលសម្រាប់បុរសនៅតាមទីប្រជុំជន និងនៅតំបន់ជនបទ។

*.5អត្រាចូលរៀនរួមនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឆ្នាំ ភជាគិត 2017ដល់ឆ្នាំ 2014◌ាគរយ*

| | 2014-2015 | | 2015-2016 | | 2016-2017 | |
|---|---|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស |
| កម្ពុជា | 25 | 24 | 25 | 24 | 27 | 24 |
| ទីប្រជុំជន | 40 | 38 | 39 | 38 | 39 | 38 |
| ទីជនបទ | 20 | 20 | 21 | 19 | 23 | 20 |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំ យុវជន និងកីឡា

ការបោះបង់សាលា

តារាង 6 បង្ហាញភាគរយនៃចំនួនមនុស្សអាយុ 6 ដល់ 17 ឆ្នាំ ដែលបានបោះបង់សាលាតាមភូមិសិក្សា និងតាមភេទ។ តាមការបង្ហាញ ភាគរយនៃអ្នកដែលបានបោះបង់សាលា បានថយចុះនៅគ្រប់ឆ្នាំសិក្សាទាំងអស់។ បុរសបោះបង់សាលា ច្រើនជាងស្ត្រីនៅគ្រប់តំបន់សម្រាប់គ្រប់ឆ្នាំសិក្សាទាំងអស់។

*.6អត្រាបោះបង់ការសិក្សាតាមកម្រិតភូមិសិក្សា ឆ្នាំ-2013 ជាភាគរយ 2016*

| ឆ្នាំសិក្សា | 2013-2014 | | 2014-2015 | | 2015-2016 | |
|---|---|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | | | | | | |
| មធ្យមសិក្សាទុតិយភូមិ | 25 | 30 | 22 | 25 | 18 | 21 |
| មធ្យមសិក្សាបឋមភូមិ | 20 | 22 | 18 | 20 | 16 | 19 |
| កម្រិតបឋមសិក្សា | 7 | 9 | 5 | 7 | 4 | 6 |
| ទីប្រជុំជន | | | | | | |
| មធ្យមសិក្សាទុតិយភូមិ | 20 | 25 | 19 | 21 | 14 | 17 |
| មធ្យមសិក្សាបឋមភូមិ | 13 | 15 | 13 | 15 | 12 | 16 |

| | | | | | | |
|---|---|---|---|---|---|---|
| កម្រិតបឋមសិក្សា | 5 | 7 | 4 | 6 | 3 | 5 |
| ទីជនបទ | | | | | | |
| មធ្យមសិក្សាទុតិយភូមិ | 28 | 32 | 24 | 28 | 20 | 23 |
| មធ្យមសិក្សាបឋមភូមិ | 22 | 24 | 20 | 22 | 16 | 19 |
| កម្រិតបឋមសិក្សា | 8 | 10 | 6 | 8 | 4 | 6 |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំ យុវជន និងកីឡា

សំណួរអំពីមូលហេតុនៃការបោះបង់ការសិក្សា ត្រូវបានសាកសួរចំពោះតែអ្នកដែលមានអាយុក្រោម 18 ឆ្នាំប៉ុណ្ណោះ ដែលពួកគេមិនបានចូលរៀន។ នៅក្នុងក្រុមនេះក្នុងឆ្នាំ2016 ក្មេងស្រីប្រហែល 43 ភាគរយ និងក្មេងប្រុសប្រហែល 35 ភាគរយនៅក្នុងតំបន់ទីប្រជុំជន និងក្មេងស្រីប្រហែល 54 ភាគរយ និងក្មេងប្រុសប្រហែល 45 ភាគរយនៅតំបន់ជនបទបានឆ្លើយថា ពួកគេមិនអាចចូលរៀនបានទេ ដោយសារតែពួកគេត្រូវធ្វើការដើម្បីរួមចំណែកដល់ការរកប្រាក់ចំណូលសម្រាប់គ្រួសារ។ ជារួម មូលហេតុនានានៃការធ្វើការងារដើម្បីរួមចំណែកដល់ការរកប្រាក់ចំណូលដល់គ្រួសារ គឺមានកម្រិត

ទាបនៅក្នុងឆ្នាំ2016 ជាជាងនៅក្នុងឆ្នាំ2014 សម្រាប់ក្មេងប្រុស និងក្មេងស្រីនៅគ្រប់តំបន់ទាំងអស់។

## 7. មូលហេតុនៃការបោះបង់សាលា ឆ្នាំ2014 និងឆ្នាំ2016

*គិតជាភាគរយ*

| មូលហេតុនៃការបោះបង់ការសិក្សា | 2014 | | 2016 | |
|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | 100 | 100 | 100 | 100 |
| មិនចង់ទៅសាលារៀន | 15 | 22 | 8 | 20 |
| រៀនមិនចេះនៅសាលារៀន | 12 | 20 | 11 | 7 |
| មិនមានសាលារៀនសមរម្យ/សាលារៀននៅឆ្ងាយពេក | 4 | 3 | 6 | 1 |
| ត្រូវជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ | 47 | 37 | 52 | 43 |
| ត្រូវជួយធ្វើការងារផ្ទះ | 11 | 7 | 7 | 11 |

| | | | | |
|---|---|---|---|---|
| ក្រីក្រពេក | 9 | 10 | 15 | 16 |
| ផ្សេងៗ | 2 | 1 | 2 | 3 |
| ទីប្រជុំជន | 100 | 100 | 100 | 100 |
| មិនចង់ទៅសាលារៀន | 16 | 23 | 3 | 20 |
| រៀនមិនចេះនៅសាលារៀន | 15 | 22 | 11 | 8 |
| មិនមានសាលារៀនសមរម្យ/សាលារៀននៅឆ្ងាយពេក | 0 | 0 | 4 | 0 |
| ត្រូវជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ | 41 | 41 | 43 | 35 |
